អាជ្ញាធរមីន

C.M.A.A

## ប្រព័ន្ធព័ត៌មានជនរងគ្រោះដោយសារមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម

# របាយការណ៍
# ស្តីពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ
# នៅខែកក្កដា ឆ្នាំ២០២៥

## សាវតារ

ប្រព័ន្ធព័ត៌មានជនរងគ្រោះដោយសារមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម (CMVIS) បានបង្កើតឡើងនៅឆ្នាំ១៩៩៤ ដោយកាកបាទក្រហមកម្ពុជា ដែលគាំទ្រថវិកា ព្រមទាំងបច្ចេកទេសពីអង្គការជនពិការអន្តរជាតិបែលហ្ស៊ិក និងអង្គការយូនីសេហ្វ។

នៅដំណាច់ឆ្នាំ២០០៩ CMVIS ត្រូវបានផ្ទេរប្រគល់ពីកាកបាទក្រហមកម្ពុជា មកស្ថិតនៅក្រោមការទទួលខុសត្រូវរបស់អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន ក្នុងការប្រមូលទិន្នន័យ វិភាគទិន្នន័យ បកស្រាយទិន្នន័យ និងការចែកចាយទិន្នន័យជនរងគ្រោះដោយសារមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម(ស.ផ.ស.) នៅក្នុងប្រទេសកម្ពុជា។

## ព័ត៌មានស្ដីពីគ្រោះថ្នាក់ និងជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ (មីន និងស.ផ.ស.)

### ១-ជនរងគ្រោះពីខែមករា ឆ្នាំ១៩៧៩ ដល់ខែកក្កដា ឆ្នាំ២០២៥

ចាប់ពីខែមករា ឆ្នាំ១៩៧៩ ដល់ខែកក្កដា ឆ្នាំ២០២៥ មានជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះចំនួន ៦៥ ១១៧នាក់ ដែលបានកត់ត្រាដោយការិយាល័យ CMVIS ក្នុងនោះរួមមាន៖

- ជនរងគ្រោះដោយសារមីន ៥១ ២២៣នាក់(៧៩%) និងស.ផ.ស. ១៣ ៨៩៤នាក់(២១%)
- ជនរងគ្រោះស្លាប់ ១៩ ៨៤៤នាក់(៣០%) របួស ៣៦ ១៧៤នាក់(៥៦%) និងពិការអវយវៈ ៩ ០៩៩នាក់(១៤%)
- ជនរងគ្រោះជាបុរស ៥២ ៧២៨នាក់(៨១%) ក្មេងប្រុសអាយុក្រោម១៨ឆ្នាំ ៦ ១២៨នាក់(៩%) ស្ត្រី ៤ ៧៩៩នាក់(៨%) ក្មេងស្រីអាយុក្រោម១៨ឆ្នាំ ១ ៣៩៩នាក់(២%) និងជនរងគ្រោះមិនស្គាល់អត្តសញ្ញាណ ៦៣នាក់(០%)។

### ២- ឧប្បត្តិហេតុគ្រោះថ្នាក់ពីខែមករា ដល់ខែកក្កដា ឆ្នាំ២០២៥

ចាប់ពីខែមករា ដល់ខែកក្កដា ឆ្នាំ២០២៥ មានឧប្បត្តិហេតុគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះចំនួន ២៤ករណី ដែលតួលេខនេះមានចំនួនដូចគ្នានឹងរយៈពេលដូចគ្នានៅឆ្នាំ២០២៤។

ក្នុងចំណោមឧប្បត្តិហេតុគ្រោះថ្នាក់ចំនួន ២៤ករណីរួមមាន៖ ឧប្បត្តិហេតុគ្រោះថ្នាក់ដោយសារមីន ១៥ករណី និងឧប្បត្តិហេតុគ្រោះថ្នាក់ដោយសារស.ផ.ស. ៩ករណី។

### ៣- ជនរងគ្រោះពីខែមករា ដល់ខែកក្កដា ឆ្នាំ២០២៥

ចាប់ពីខែមករា ដល់ខែកក្កដា ឆ្នាំ២០២៥ មានជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះចំនួន ៣១នាក់។ តួលេខនេះបានថយចុះ ១៦% បើប្រៀបធៀបនឹងរយៈពេលដូចគ្នានៅឆ្នាំ២០២៤ ដែលមានជនរងគ្រោះចំនួន ៣៧នាក់។

ក្នុងចំណោមជនរងគ្រោះចំនួន ៣១នាក់ រួមមាន៖

- ជនរងគ្រោះដោយសារមីន ១៧នាក់ និងជនរងគ្រោះដោយសារស.ផ.ស. ១៤នាក់
- ជនរងគ្រោះស្លាប់ ១០នាក់ របួស ១៨នាក់ និងពិការអវយវៈ ៣នាក់
- ជនរងគ្រោះជាបុរស ២៣នាក់ ជាស្ត្រី ២នាក់ ជាក្មេងប្រុសអាយុក្រោម១៨ឆ្នាំ ៥នាក់ និងជាក្មេងស្រីអាយុក្រោម១៨ឆ្នាំ ១នាក់។

## ៤- ឧប្បត្តិហេតុគ្រោះថ្នាក់ក្នុងខែកក្កដា ឆ្នាំ២០២៥

នៅខែកក្កដា ឆ្នាំ២០២៥ មានឧប្បត្តិហេតុគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះចំនួន ៤ករណី បានកើតឡើងនៅខេត្តព្រះវិហារ និងខេត្តបាត់ដំបង។ តួលេខនេះបានកើនឡើង ៣៣% បើប្រៀបធៀបនឹងខែកក្កដា ឆ្នាំ២០២៤ ដែលមានឧប្បត្តិហេតុគ្រោះថ្នាក់ ៣ករណី។

ព័ត៌មានឧប្បត្តិហេតុគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះនៅខែកក្កដា ឆ្នាំ២០២៥

- ឧប្បត្តិហេតុគ្រោះថ្នាក់ដោយសារមីន ២ករណី កើតឡើងលើដីពុំមានការប្រើប្រាស់ និង ១ករណី កើតឡើងលើដីចម្ការ
- ឧប្បត្តិហេតុគ្រោះថ្នាក់ដោយសារស.ផ.ស. ១ករណី បានកើតឡើងនៅក្នុងភូមិ។

## ៥- ជនរងគ្រោះក្នុងខែកក្កដា ឆ្នាំ២០២៥

នៅខែកក្កដា ឆ្នាំ២០២៥ មានជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះចំនួន ៧នាក់។ តួលេខនេះបានកើនឡើង ២៥០% បើប្រៀបធៀបនឹងខែកក្កដា ឆ្នាំ២០២៤ ដែលមានជនរងគ្រោះចំនួន ២នាក់។

ព័ត៌មានជនរងគ្រោះមានដូចខាងក្រោម៖

- ជនរងគ្រោះជាបុរស ៥នាក់ បានរងគ្រោះដោយសារមីន និង២នាក់បានរងគ្រោះដោយសារ ស.ផ.ស.
- ជនរងគ្រោះរបួស ៥នាក់ ពិការអវយវៈ ១នាក់ និងស្លាប់ ១នាក់
- សកម្មភាពនៅពេលគ្រោះថ្នាក់គឺ៖ ការសម្អាតដីដើម្បីធ្វើកសិកម្ម ១នាក់ ការលេងគ្រាប់ ២នាក់ និងការធ្វើសកម្មភាពយោធា ៤នាក់។

## ៦- ផលប៉ះពាល់ពីតំបន់គ្រោះថ្នាក់ពីខែមករា ឆ្នាំ២០២៤ ដល់ខែកក្កដា ឆ្នាំ២០២៥ (ជនរងគ្រោះ ៨០នាក់)

- ខេត្តចំនួន ៥ ដែលទទួលរងផលប៉ះពាល់ខ្លាំងបំផុតមានជនរងគ្រោះ ៥៦% នៃជនរងគ្រោះសរុប
- ស្រុកចំនួន ១០ ដែលទទួលរងផលប៉ះពាល់ខ្លាំងបំផុតមានជនរងគ្រោះ ៦៥% នៃជនរងគ្រោះសរុប
- ឃុំចំនួន ១០ ដែលទទួលរងផលប៉ះពាល់ខ្លាំងបំផុតមានជនរងគ្រោះ ៥៤% នៃជនរងគ្រោះសរុប។

*ព័ត៌មានលម្អិត សូមមើលទំព័រទី៧*

# ទីតាំងគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ នៅខែកក្កដា ឆ្នាំ២០២៥
# ឧប្បត្តិហេតុ ៤ករណី ជនរងគ្រោះ ៧នាក់




Produced by CMVIS, Aug 2025

ព័ត៌មានលម្អិតទាក់ទងនឹងព័ត៌មានអំពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ សូមទំនាក់ទំនងមកការិយាល័យ CMVIS តាមរយៈអាស័យដ្ឋានអ៊ីម៉ែល: ketya@cmaa.gov.kh

# របាយការណ៍ជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះពីខែមករា ឆ្នាំ២០២២ ដល់ខែកក្កដា ឆ្នាំ២០២៥

| | ជនរងគ្រោះតាមខែ | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ឆ្នាំ/ខែ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | សរុប |
| **2022** | **11** | **9** | **7** | **7** | **5** | **1** | **0** | **0** | **0** | **0** | **0** | **1** | **41** |
| *ការបូកបណ្ដាក់ ឆ្នាំ2022* | *11* | *20* | *27* | *34* | *39* | *40* | *40* | *40* | *40* | *40* | *40* | *41* | |
| **2023** | **3** | **5** | **4** | **0** | **7** | **2** | **2** | **3** | **1** | **2** | **1** | **2** | **32** |
| *ការបូកបណ្ដាក់ ឆ្នាំ2023* | 3 | 8 | 12 | 12 | 19 | 21 | 23 | 26 | 27 | 29 | 30 | 32 | |
| *ការប្រែប្រួលភាគរយ 2022 ធៀប 2023* | -73 | -60 | -56 | -65 | -51 | -48 | -43 | -35 | -33 | -28 | -25 | -22 | |
| **2024** | **3** | **3** | **5** | **12** | **7** | **5** | **2** | **1** | **1** | **6** | **2** | **2** | **49** |
| *ការប្រែប្រួលតួលេខតាមខែធៀប 2023* | 0 | -2 | 1 | 12 | 0 | 3 | 0 | -2 | 0 | 4 | 1 | 0 | |
| *ការប្រែប្រួលភាគរយតាមខែធៀប 2023* | 0 | -40 | 25 | 100 | 0 | 150 | 0 | -67 | 0 | 200 | 100 | 0 | |
| *ការបូកបណ្ដាក់ ឆ្នាំ2024* | ***3*** | ***6*** | ***11*** | ***23*** | ***30*** | ***35*** | ***37*** | ***38*** | ***39*** | ***45*** | ***47*** | ***49*** | |
| *ការប្រែប្រួលភាគរយ 2023 ធៀប 2024* | 0 | -25 | -8 | 92 | 58 | 67 | 61 | 46 | 44 | 55 | 57 | 53 | |
| **2025** | **6** | **6** | **1** | **5** | **2** | **4** | **7** | | | | | | **31** |
| *ការប្រែប្រួលតួលេខតាមខែធៀប 2024* | 3 | 3 | -4 | -7 | -5 | -1 | 5 | | | | | | |
| *ការប្រែប្រួលភាគរយតាមខែធៀប 2024* | 100 | 100 | -80 | -58 | -71 | -20 | 250 | | | | | | |
| *ការបូកបណ្ដាក់ ឆ្នាំ2025* | ***6*** | 12 | ***13*** | ***18*** | ***20*** | ***24*** | ***31*** | | | | | | |
| *ការប្រែប្រួលភាគរយ 2024 ធៀប 2025* | 100 | 100 | 18 | -22 | -33 | -31 | -16 | | | | | | |

ចំណាំៈ តួលេខជនរងគ្រោះសម្រាប់ខែបន្តបន្ទាប់ទៀត នៃដំណើរការប្រមូលទិន្នន័យនឹងស្រាវជ្រាវឱ្យទាន់ពេលវេលា



## ជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ចាប់ពីខែមករា ឆ្នាំ២០២៤ ដល់ខែកក្កដា ឆ្នាំ២០២៥

### រាជធានីខេត្តត្រូវបានតម្រៀបតាមលំដាប់ចុះនៃផលបូកសរុបជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ក្នុងឆ្នាំ២០២៤ និងឆ្នាំ២០២៥

| | មករា24 | កុម្ភៈ24 | មីនា24 | មេសា24 | ឧសភា24 | មិថុនា24 | កក្កដា24 | សីហា24 | កញ្ញា24 | តុលា24 | វិច្ឆិកា24 | ធ្នូ24 | សរុប2024 | មករា25 | កុម្ភៈ25 | មីនា25 | មេសា25 | ឧសភា25 | មិថុនា25 | កក្កដា25 | សីហា25 | កញ្ញា25 | តុលា25 | វិច្ឆិកា25 | ធ្នូ25 | សរុប2025 | សរុប | ការបូកបណ្ដាក់លើសរុប | ភាគរយនៃសរុប | ការបូកបណ្ដាក់លើភាគរយសរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ឈ្មោះខេត្ត | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | 2024-2025 | | | |
| បាត់ដំបង | 0 | 1 | 2 | 0 | 0 | 0 | 0 | 1 | 0 | 0 | 1 | 0 | 5 | 3 | 0 | 0 | 3 | 0 | 0 | 3 | 0 | 0 | 0 | 0 | 0 | 9 | 14 | 14 | 17.5 | 18 |
| ព្រះវិហារ | 0 | 0 | 0 | 0 | 2 | 2 | 0 | 0 | 0 | 0 | 0 | 0 | 4 | 0 | 0 | 1 | 0 | 0 | 1 | 4 | 0 | 0 | 0 | 0 | 0 | 6 | 10 | 24 | 12.5 | 30 |
| ឧត្តរមានជ័យ | 0 | 0 | 3 | 1 | 0 | 0 | 0 | 0 | 0 | 0 | 1 | 0 | 5 | 2 | 0 | 0 | 1 | 0 | 1 | 0 | 0 | 0 | 0 | 0 | 0 | 4 | 9 | 33 | 11.3 | 41 |
| ពោធិ៍សាត់ | 3 | 0 | 0 | 0 | 0 | 1 | 0 | 0 | 0 | 0 | 0 | 0 | 4 | 0 | 1 | 0 | 0 | 0 | 1 | 0 | 0 | 0 | 0 | 0 | 0 | 2 | 6 | 39 | 7.5 | 49 |
| មណ្ឌលគិរី | 0 | 0 | 0 | 6 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 6 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 6 | 45 | 7.5 | 56 |
| កំពង់ធំ | 0 | 0 | 0 | 4 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 4 | 0 | 2 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 2 | 6 | 51 | 7.5 | 64 |
| កំពត | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 6 | 0 | 0 | 6 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 6 | 57 | 7.5 | 71 |
| បន្ទាយមានជ័យ | 0 | 2 | 0 | 0 | 1 | 1 | 0 | 0 | 1 | 0 | 0 | 0 | 5 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 5 | 62 | 6.3 | 78 |
| កំពង់ឆ្នាំង | 0 | 0 | 0 | 0 | 4 | 0 | 0 | 0 | 0 | 0 | 0 | 0 | 4 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 4 | 66 | 5 | 83 |
| កោះកុង | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 2 | 2 | 0 | 0 | 0 | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 1 | 3 | 69 | 3.8 | 86 |
| ត្បូងឃ្មុំ | 0 | 0 | 0 | 0 | 0 | 1 | 1 | 0 | 0 | 0 | 0 | 0 | 2 | 0 | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 1 | 3 | 72 | 3.8 | 90 |
| ក្រចេះ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 1 | 0 | 0 | 0 | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | 2 | 2 | 74 | 2.5 | 93 |
| សៀមរាប | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 2 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 2 | 2 | 76 | 2.5 | 95 |
| ប៉ៃលិន | 0 | 0 | 0 | 0 | 0 | 0 | 1 | 0 | 0 | 0 | 0 | 0 | 1 | 0 | 0 | 0 | 0 | 0 | 1 | 0 | 0 | 0 | 0 | 0 | 0 | 1 | 2 | 78 | 2.5 | 98 |
| ព្រះសីហនុ | 0 | 0 | 0 | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 1 | 79 | 1.3 | 99 |
| ស្វាយរៀង | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | 1 | 1 | 80 | 1.3 | 100 |
| កំពង់ចាម | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 80 | 0 | 100 |
| កំពង់ស្ពឺ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 80 | 0 | 100 |
| កណ្ដាល | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 80 | 0 | 100 |
| ព្រៃវែង | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 80 | 0 | 100 |
| រតនគិរី | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 80 | 0 | 100 |
| ស្ទឹងត្រែង | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 80 | 0 | 100 |
| តាកែវ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 80 | 0 | 100 |
| កែប | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 80 | 0 | 100 |
| ភ្នំពេញ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 80 | 0 | 100 |
| សរុប | 3 | 3 | 5 | 12 | 7 | 5 | 2 | 1 | 1 | 6 | 2 | 2 | 49 | 6 | 6 | 1 | 5 | 2 | 4 | 7 | 0 | 0 | 0 | 0 | 0 | 31 | 80 | | | |



## ខេត្តចំនួន 5 ទទួលរងឥទ្ធិពលខ្លាំងជាងគេ ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ

ត្រូវបានតម្រៀបតាមលំដាប់ចុះ នៃផលបូកសរុបជនរងគ្រោះ

ពីខែមករា ឆ្នាំ២០២៤ ដល់ខែកក្កដា ឆ្នាំ២០២៥

| លំដាប់ | ខេត្ត | អ្នករងគ្រោះមីន | អ្នករងគ្រោះសំណល់ជាតិផ្ទុះពីសង្គ្រាម | ផលបូកសរុបអ្នករងគ្រោះ | ការបូកបណ្តាក់លើផលបូកសរុប |
|---|---|---|---|---|---|
| 1 | បាត់ដំបង | 8 | 6 | **14** | 14 |
| 2 | ព្រះវិហារ | 9 | 1 | **10** | 24 |
| 3 | ឧត្តរមានជ័យ | 9 | 0 | **9** | 33 |
| 4 | កំពង់ធំ | 0 | 6 | **6** | 39 |
| 5 | មណ្ឌលគិរី | 0 | 6 | **6** | 45 |

## ស្រុកចំនួន 10 ទទួលរងឥទ្ធិពលខ្លាំងជាងគេ ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ

ត្រូវបានតម្រៀបតាមលំដាប់ចុះ នៃផលបូកសរុបជនរងគ្រោះ

ពីខែមករា ឆ្នាំ២០២៤ ដល់ខែកក្កដា ឆ្នាំ២០២៥

| លំដាប់ | ស្រុក | ខេត្ត | អ្នករងគ្រោះមីន | អ្នករងគ្រោះសំណល់ជាតិផ្ទុះពីសង្គ្រាម | ផលបូកសរុបអ្នករងគ្រោះ | ការបូកបណ្តាក់លើផលបូកសរុប |
|---|---|---|---|---|---|---|
| 1 | ជាំក្សាន្ត | ព្រះវិហារ | 9 | 1 | **10** | 10 |
| 2 | ស្ទោង | កំពង់ធំ | 0 | 6 | **6** | 16 |
| 3 | បន្ទាយមាស | កំពត | 0 | 6 | **6** | 22 |
| 4 | វាលវែង | ពោធិ៍សាត់ | 6 | 0 | **6** | 28 |
| 5 | សែនមនោរម្យ | មណ្ឌលគិរី | 0 | 6 | **6** | 34 |
| 6 | រតនៈមណ្ឌល | បាត់ដំបង | 3 | 1 | **4** | 38 |
| 7 | បរិបូណ៌ | កំពង់ឆ្នាំង | 0 | 4 | **4** | 42 |
| 8 | ត្រពាំងប្រាសាទ | ឧត្តរមានជ័យ | 4 | 0 | **4** | 46 |
| 9 | សំឡូត | បាត់ដំបង | 3 | 0 | **3** | 49 |
| 10 | បាណន់ | បាត់ដំបង | 0 | 3 | **3** | 52 |

## ឃុំចំនួន 10 ទទួលរងឥទ្ធិពលខ្លាំងជាងគេ ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ

ត្រូវបានតម្រៀបតាមលំដាប់ចុះ នៃផលបូកសរុបជនរងគ្រោះ

ពីខែមករា ឆ្នាំ២០២៤ ដល់ខែកក្កដា ឆ្នាំ២០២៥

| លំដាប់ | ឃុំ | ស្រុក | ខេត្ត | អ្នករងគ្រោះមីន | អ្នករងគ្រោះសំណល់ជាតិផ្ទុះពីសង្គ្រាម | ផលបូកសរុបអ្នករងគ្រោះ | ការបូកបណ្តាក់លើផលបូកសរុប |
|---|---|---|---|---|---|---|---|
| 1 | ថ្មដា | វាលវែង | ពោធិ៍សាត់ | 6 | 0 | **6** | 6 |
| 2 | ទូកមាសខាងលេច | បន្ទាយមាស | កំពត | 0 | 6 | **6** | 12 |
| 3 | មរកត | ជាំក្សាន្ត | ព្រះវិហារ | 5 | 1 | **6** | 18 |
| 4 | រមនា | សែនមនោរម្យ | មណ្ឌលគិរី | 0 | 6 | **6** | 24 |
| 5 | ផ្លូវទូក | បរិបូណ៌ | កំពង់ឆ្នាំង | 0 | 4 | **4** | 28 |
| 6 | រុងរឿង | ស្ទោង | កំពង់ធំ | 0 | 4 | **4** | 32 |
| 7 | បាក់ខ្លង | មណ្ឌលសីមា | កោះកុង | 1 | 2 | **3** | 35 |
| 8 | ចែងមានជ័យ | បាណន់ | បាត់ដំបង | 0 | 3 | **3** | 38 |
| 9 | ត្រពាំងប្រិយ៍ | អន្លង់វែង | ឧត្តរមានជ័យ | 3 | 0 | **3** | 41 |
| 10 | ពពក | ស្ទោង | កំពង់ធំ | 0 | 2 | **2** | 43 |

# ការផ្ទុះបញ្ចាំងទូទៅលើជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ

អំឡុងពេល: មករា ឆ្នាំ២០២៤ - កក្កដា ឆ្នាំ២០២៥

ចំនួនសរុបនៃជនរងគ្រោះក្នុងអំឡុងពេលរាយការណ៍: ៨០

## ការបែងចែកតាមប្រភេទយុទ្ធភណ្ឌគ្រឿងផ្ទុះ




## មូលហេតុបណ្តាលឱ្យរងគ្រោះ




## លក្ខណៈនៃអ្នករងគ្រោះ




## ការផ្ទុះបញ្ចាំងទូទៅលើករណីរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ












អំឡុងពេលៈ ខែមករា ឆ្នាំ២០២៤ - ខែកក្កដា ឆ្នាំ២០២៥

ចំនួនសរុបនៃជនរងគ្រោះ ក្នុងអំឡុងពេលរាយការណ៍: ៨០

## សកម្មភាពដែលបណ្ដាលឱ្យគ្រោះថ្នាក់យុទ្ធភណ្ឌគ្រឿងផ្ទុះ បែងចែកទៅតាមប្រភេទជនរងគ្រោះ

| បុរស | ស្ត្រី | ក្មេង | សរុប |
|---|---|---|---|
| 53 | 5 | 22 | 80 |




## សកម្មភាពរបស់ជនរងគ្រោះនៅពេលដែលគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ

### សកម្មភាពដែលបណ្ដាលឱ្យផ្ទុះមីន




### សកម្មភាពដែលបណ្ដាលឱ្យផ្ទុះសំណល់ជាតិផ្ទុះពីសង្គ្រាម




## ឧប្បត្តិហេតុគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ តាមលក្ខណៈភូមិសាស្ត្រដី

### លក្ខណៈភូមិសាស្ត្រដីដែលបណ្ដាលឱ្យផ្ទុះមីន




### លក្ខណៈភូមិសាស្ត្រដីដែលបណ្ដាលឱ្យផ្ទុះសំណល់ជាតិផ្ទុះពីសង្គ្រាម

